# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1108

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : ការពង្រឹងស្ថាប័ននៅកម្ពុជាសម្រាប់ការអនុវត្តលើកិច្ចការសម្របសម្រួល និងប្រសិទ្ធភាពនៃកិច្ចព្រមព្រៀងការគ្រប់គ្រងសារធាតុគីមី និងសំណល់គ្រោះថ្នាក់ អន្តរជាតិ

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 01/01/20 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/12/22 |

៣. ចំណាយគម្រោងសរុប $330,500

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងបរិស្ថាន

| | |
|---|---|
| RESPONSIBLE UNIT | Directorate General of Environmental Protection, Department of Hazardous Substance Management |
| អង្គភាពទទួលខុសត្រូវ | អគ្គនាយកដ្ឋានគាំពារបរិស្ថាន, នាយកដ្ឋានគ្រប់គ្រង សារធាតុគ្រោះថ្នាក់ |

៥. ស្ថានភាពគម្រោង គម្រោងដែលបានបញ្ចប់

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងជំនួយបច្ចេកទេស

៧. ប្រភពហិរញ្ញប្បទាន៖ ជំនួយឥតសំណង

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី២- ការប្រកាន់ខ្ជាប់នូវនយោបាយការបរទេសឯករាជ្យ ផ្អែកលើច្បាប់ និងឈ្លាសវៃ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងនេះនឹងចូលរួមចំណែកក្នុងការលើកកម្ពស់សមត្ថភាពស្ថានប័នពាក់ពន្ធ័សម្រាប់ការអនុវត្តអនុសញ្ញាពាក់ពន្ធ័នឹងសារធាតុគីមីគ្រោ ០ះថ្នាក់ និងសំណល់ សំដៅធានាដល់កិច្ចគាំពារបរិស្ថាន និងការពារសុខភាពមនុស្ស។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍនិវិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

បរិស្ថាន និងការអភិរក្ស

**១២. ទីតាំងអនុវត្តគម្រោង** ( ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង )

រាជធានីភ្នំពេញ,

**១៣. គោលបំណងរបស់គម្រោង** ( ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង )

ពង្រឹងការសំរបសំរួលអន្តរវិស័យ និងកសាងសមត្ថភាពថ្នាក់ជាតិសម្រាប់ការតាមដានការអនុវត្ត MEA និង យុទ្ធសាស្ត្រ SAICM ព្រមទាំងការរាយការណ៍ និងការឆ្លើយតបនឹងបដិជានច្បាប់

បង្កើត និងរៀបចំកម្មវិធីគ្រប់គ្រង និងចែករំលែកព័ត៌មានថ្នាក់ជាតិឱ្យបានទូលំទូលាយ

បង្កើត និងរៀបចំកម្មវិធីបណ្តុះបណ្តាលស្តីពីការអនុវត្តថ្នាក់ជាតិនៃ MEAs និងយុទ្ធសាស្ត្រ SAICM សម្រាប់ជនបង្គោលជាតិនៃអនុសញ្ញាទាំង៣ មានអនុសញ្ញាបាសែល រ៉ូតឌឺដាម និងស្តុកខូម (BRS) និងអនុសញ្ញា-មីណាម៉ាតា ព្រមទាំងជនបង្គោល SAICM និងអង្គការ GEF ហើយចំពោះថ្នាក់ដឹកនាំឬអ្នកសម្រេចចិត្ត និង ភាគីពាក់ព័ន្ធផ្សេងទៀតរួមមាន បណ្តុះបណ្តាលគ្រូបង្គោលសម្រាប់បណ្តុះបណ្តាលបន្តដើម្បីឈានសម្រេច បាននូវបរិមាណច្រើន

រៀបចំអនុវត្តយុទ្ធនាការលើកកម្ពស់ការយល់ដឹង និងការអប់រំ។

**១៤. ការពិពណ៌នាអំពីគម្រោង** ( ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង )

បង្កើតហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងគម្រោង និងអនុវត្តការងារគម្រោង

រៀបចំគណៈកម្មាធិការដែលមានស្រាប់ និងបង្កើតគណៈកម្មាធិការសម្របសម្រួលគម្រោងដើម្បីត្រួតពិនិត្យ ការអនុវត្តគម្រោង

បង្កើតល័ក្ខខ័ណ្ឌការងារសម្រាប់គណៈកម្មាធិការសម្របសម្រួលគម្រោង

កំណត់លេខាធិការដ្ឋានគម្រោង និងរៀបចំសិក្ខាសាលាចាប់ផ្ដើមគម្រោង

រៀបចំពេលវេលាសម្រាប់កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលគម្រោង

ពង្រឹងការសម្របសម្រួលអន្តរវិស័យ និងសមត្ថភាពជាតិសម្រាប់ត្រួតពិនិត្យការអនុវត្ត MEA និងកម្មវិធី SAICM លើការអនុវត្តការរាយការណ៍

ពង្រឹងយន្តការសម្របសម្រួលអន្តរវិស័យដែលមានស្រាប់

រៀបចំរបាយការណ៍ស្តីពីការវិភាគជាលក្ខណៈប្រព័ន្ធនៃកាតព្វកិច្ចជាតិក្រោមកម្មវិធី MEA នីមួយៗ រួមមានតម្រូវការរបាយការណ៍ កាលវិភាគ និងបញ្ហាឆ្លើយតបតាមបទដ្ឋានគតិយុត្ត

បង្កើត និងបណ្តុះបណ្តាលលើកម្មវិធីមួយដើម្បីតាមដានការអនុវត្ត និងរាយការណ៍ថ្នាក់ជាតិចំពោះ MEAs និងសារធាតុគីមីព្រមទាំងសំណល់ដែលពាក់ព័ន្ធ។

រៀបចំយុទ្ធសាស្ត្រថ្នាក់ជាតិសម្រាប់សកម្មភាពសមាហរណកម្មលើការអនុវត្តថ្នាក់ជាតិនៃ MEAs និងយុទ្ធសាស្ត្រ SAICM

រៀបចំកិច្ចប្រជុំសម្របសម្រួលយន្តការទៀងទាត់

បង្កើតកម្មវិធីគ្រប់គ្រងនិងចែករំលែកព័ត៌មានថ្នាក់ជាតិដ៏ទូលំទូលាយ

ប្រមូល និងរៀបចំធនធាន

រៀបចំទម្រង់ព័ត៌មាន

សាកល្បង បើកដំណើរការ និងបណ្តុះបណ្តាលអំពីទម្រង់ព័ត៌មាន

រៀបចំកម្មវិធីបណ្តុះបណ្តាលស្តីពីការអនុវត្តថ្នាក់ជាតិនៃ MEAs និងយុទ្ធសាស្ត្រ SAICM សម្រាប់ជនបង្គោលជាតិនៃអនុសញ្ញាប៉ាសែល រ៉ូតធីដាម និងស្តុកខូម (BRS) និងមីណាម៉ាតា ព្រមទាំងជនបង្គោលជាតិនៃកម្មវិធី SAICM និងអង្គការ GEF ហើយចំពោះអ្នកសំរេចចិត្តពាក់ព័ន្ធនិងអ្នកពាក់ព័ន្ធផ្សេងទៀត។

កំណត់តម្រូវការ រៀបចំកម្មវិធីនិងសំភារៈ

រៀបចំសិក្ខាសាលាបណ្តុះបណ្តាល និងបណ្តុះបណ្តាលគ្រូបង្គោល

រៀបចំសិក្ខាសាលាថ្នាក់តំបន់ដែលប្រតិបត្តិដោយគ្រូបង្គោល

អនុវត្តយុទ្ធនាការលើកកម្ពស់ការយល់ដឹងនិងការអប់រំ

កំណត់តម្រូវការ និងគោលដៅអ្នកទទួល

រៀបចំវិធីសាស្ត្រលើកកម្ពស់ការយល់ដឹង និងការអប់រំ ព្រមទាំងផ្តល់នូវសម្ភារៈ

អនុវត្តយុទ្ធនាការលើកកម្ពស់ការយល់ដឹង និងការអប់រំ។

**១៥. យុត្តិកម្មលើគម្រោង** (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

ការពង្រឹងស្ថាប័ននៅកម្ពុជាសម្រាប់ការអនុវត្តលើកិច្ចការសម្របសម្រួល និងកិច្ចព្រមព្រៀងការគ្រប់គ្រងសារធាតុគីមី និងសំណល់គ្រោះថ្នាក់អន្តរជាតិ គឺជាផ្នែកមួយដ៏សំខាន់ក្នុងការបំពេញកាតព្វកិច្ចជារដ្ឋភាគី ប្រកបដោយប្រសិទ្ធភាព។

**១៦. ផលប្រយោជន៍របស់គម្រោង** (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

មន្ត្រីនៃស្ថាប័នពាក់ពន្ធ័នឹងទទួលបានចំណេះដឹង និងការលើកកម្ពស់សមត្ថភាពបន្ថែមទៀតអំពីកិច្ចព្រមព្រៀងពហុភាគីវិស័យបរិស្ថានតាមរយៈការចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងពត័មានអ៊ិនធ្យាញ់ ដែលនឹងត្រូវរៀបចំក្រោមក្របខណ្ឌ័សកម្មភាពនៃគម្រោងនេះ។

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | **គ្មាន** |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | **មិនទានចាប់ផ្តើម** |

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**គម្រោងនេះនឹងចូលរួមចំណែកដល់កិច្ចគាំពារបរិស្ថាន និងការពារសុខភាពមនុស្ស តាមរយៈការលើកកម្ពស់ការអនុវត្តកិច្ចព្រមព្រៀងបរិស្ថានពហុភាគី ដោយចាត់វិធានការណ៍ចាំបាច់សម្រាប់គ្រប់គ្រងសារធាតុគ្រោះថ្នាក់ និងសំណល់គ្រោះថ្នាក់ប្រកបដោយសុវត្ថិភាពបរិស្ថាន។ ជាមួយគ្នានេះ គម្រោងនេះក៏នឹងចូលរួមក្នុងការកាត់បន្ថយភាពក្រីក្រតាមរយៈការការពារបរិស្ថាន និងការពារសុខភាពមនុស្សដែលបង្កឡើងដោយសារជាតុពុល និងសំណល់គ្រោះថ្នាក់ សំដៅលើកកម្ពស់គុណភាពបរិស្ថានឱ្យកាន់តែប្រសើរបន្ថែមទៀតសម្រាប់ការរស់នៅរបស់ប្រជាជនប្រកបដោយសុខមាលភាព។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**គម្រោងនេះនឹងផ្តល់ចំណេះដឹង និងបង្កើនសមត្ថភាពយេនឌ័រសំដៅលើកកម្ពស់តួនាទីយេនឌ័រអោយកាន់តែប្រសើរបន្ថែមទៀតក្នុងការអនុវត្តការងារពាក់ពន្ធ័នឹងការគ្រប់គ្រងសារជាតុគ្រោះថ្នាក់ និងសំណល់។ ការអនុវត្តគម្រោងនេះបានជំរុញលើកទឹកដល់ការចូលរួមរបស់ស្ត្រី ដូចជាការចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំពិភាក្សា។ល។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**ក្រសួងមានមន្ត្រីជំនាញដែលមានសមត្ថភាព និងបទពិសោធន៍ខ្ពស់ពាក់ពន្ធ័នឹងការងារកិច្ចព្រមព្រៀងបរិស្ថាន ពហុភាគីសម្រាប់ការអនុវត្តគម្រោងនេះ។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**សកម្មភាពគម្រោងមួយចំនួនត្រូវបានពន្យាពេលអនុវត្តដោយសារបេញ្ហាការរាតត្បាតនៃជម្ងឺកូវីត១៩ ដូចជាការរៀបចំកិច្ចប្រជុំ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលជាដើម។**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**គម្រោងត្រូវបានផ្តល់ថវិកាពី GEF និងជំនួយបច្ចេកទេសពីអង្គការ UNEP ក្នុងការសម្របសម្រួលអនុវត្តដោយ ក្រសួងបរិស្ថាន។**

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2021 | | 2022 | 2023 | 2024 | 2025 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ដាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2023-2025 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 55.5 | 0.0 | 29.2 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 41.5 | 0.0 | 22.1 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 14.0 | 0.0 | 7.1 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 78.1 | 0.0 | 63.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 8.5 | 0.0 | 5.1 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 1.6 | 0.0 | 0.8 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 51.9 | 0.0 | 40.9 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 16.1 | 0.0 | 16.2 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 133.6 | 0.0 | 92.2 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2021 | | 2022 | 2023 | 2024 | 2025 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2023-2025 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 27.0 | 0.0 | 20.5 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 27.0 | 0.0 | 20.5 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | 106.6 | 0.0 | 71.7 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| United Nation Environment Programme | 103.4 | 0.0 | 68.5 | 0.0 | 0.0 | 0.0 | 0.0 | |
| United Nations Institute for Training and Research | 3.2 | 0.0 | 3.2 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 133.6 | 0.0 | 92.2 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: